ព្រះរាជបណ្ណាល័យកម្ពុជា

# កម្ពុជសុរិយា

## សៀវភៅចេញរាល់ខែ ពីព្រះរាជបណ្ណាល័យ

## ឆ្នាំគម្រប់បី

ខ្សែ ៦

ក្រុងភ្នំពេញ

រោងពុម្ពរាជការ គូវែរណើម៉ង់

គ្រិ. ឆ្នាំ ១៩៣០

ពុ.ស ២៤៧៣

អ្នកទទួលខុសត្រូវ ជុំ-ម៉ៅ

# បញ្ជីរឿង

ទំព័រ


១- ជាឞកថា ក្រុមព្រះជំរុងរាជានុភាព អំពីមូលហេតុនៃការព្រះសាសនាក្នុងស្រុកសៀម ព្រះមហាពិទូរក្រសេម គន្ថរចនបណ្ឌិត នៅព្រះរាជបណ្ណាល័យ ប្រែពីភាសាសៀមមកជាភាសាខ្មែរ (តចប់) . . . . . ១៥៥

២- មិលិន្ទបញ្ហា ព្រះគ្រូវិមលបញ្ញា អ៊ុម ស៊ូរ អាចារ្យនៅព្រះរាជបណ្ណាល័យកម្ពុជា ប្រែពីបាលីមកជាភាសាខ្មែរ (ត) . . . . .

៣- គតិលោក ឬ ច្បាប់ទូន្មានខ្លួន ឧកញ៉ាសុត្តន្តប្រីជា ឥន្ទ រៀបរៀង (ត)

( គតិលោក និង មិលិន្ទបញ្ហា មិនបានចុះក្នុងនេះទេ ព្រោះមានបោះសៀវភៅដោយឡែកហើយ ) . . . . . .

៤- ប្រវត្តិរបស់វត្តពោធិភិល (បាត់ដំបង) អាចារ្យ អ៊ីវ-ទួត ចៅអធិការវត្តនេះរៀបរៀង . . . . . . . . . . . . . ១៦៥

# មូលហេតុនៃការព្រះសាសនាក្នុងប្រទេសស្យាម

## បាឋកថា របស់ក្រុមព្រះដំរុងរាជានុភាព

## ព្រះមហាពិទូរ ក្រសេម

គន្ថរចនបណ្ឌិត នៅព្រះរាជបណ្ណាល័យកម្ពុជា ប្រែពីភាសាសៀមមកជាភាសាខ្មែរ

( តចប់ )

---

៧. ទម្រោយរបស់វត្តក្នុងប្រទេសស្យាមសព្វថ្ងៃនេះ កើតឡើងកាលទទួលលទ្ធិព្រះពុទ្ធសាសនាហីនយាន យ៉ាងលង្កាវង្សមកកាន់នោះមានច្រើនយ៉ាង គឺត្រឡប់សាងព្រះស្តូបដែលបញ្ចុះ ព្រះបរមធាតុជាគោលចារិកវត្តតាមដើម ដោយពួកលង្កាតាំងតម្រាព្រះធាតុ ថាអាចនឹងស្គាល់បានដោយលក្ខណៈ ហើយគេបានក្នុងលង្កាទ្វីប ជាហេតុឲ្យត្រឡប់រកព្រះបរមធាតុបានងាយឡើងៗ យ៉ាង កើតមានរោងឧបោសថនឹងមានពទ្ធសីមា ព្រោះវេលានោះព្រះសង្ឃទោះបីនៅមិនទាន់មានចំនួនក្រាស់ក្រៃល ក៏មានច្រើនពួកច្រើនគណៈ ហើយកាន់លទ្ធិផ្សេងៗ ជាហេតុឲ្យរង្កៀស ដែលនឹងធ្វើសង្ឃកម្មរួមគ្នា ត្រង់នេះនឹងពោលសេចក្តីអធិប្បាយ អំពីរឿងសង្ឃកម្មជ្រែកជ្រៀតបន្តិចចុះដែលមុខគួរពិកាល់ ឯរឿងសង្ឃកម្មនោះ មានអាការដូចគ្នានឹងការតាំងសមាគមក្នុងបច្ចុប្បន្ននេះឯង ពោលគឺបណ្តាអ្នកដែលបានទទួលឧបសម្បទា ជាភិក្ខុរាប់ថា

ជាក្រុមប្រឹក្សាក្នុងសង្ឃសមាគម   កាលនឹងធ្វើការអ្វីមួយដែលទាក់ទិន
ដោយសង្ឃកម្មទៅ   ដូចយ៉ាងនឹងទទួលអ្នកស្រុកចូលបួសជាសមាគម
ផងគ្នាជាដើម  ក៏តោងប្រជុំព្រះសង្ឃទាំងអស់ឲ្យរើស  ដូចយ៉ាងការរើស
ក្រុមប្រឹក្សានៃសមាគមក្នុងបច្ចុប្បន្ននេះ   លុះតែឃើញស្រួលព្រមគ្នាទើប
ទទួលបាន  សង្ឃកម្មយ៉ាងដទៃហេតុដល់ទទួលកឋិន  ក៏តោងប្រជុំដូច
គ្នា  កាលមានព្រះសង្ឃច្រើនឡើង  តាំងពីគ្រាពុទ្ធកាល  នឹងហៅមក
ប្រជុំគ្នាឲ្យបានទាំងអស់ជាការលំបាកច្រើន  ទើបបានកើតទីកំណត់សីមា
ដូចយ៉ាងកំណត់យកផ្ទៃទីមួយជាខេត្តដែន  វេលាមានការប្រជុំក៏ហៅតែ
ព្រះសង្ឃដែលនៅក្នុងដែនខណ្ឌនោះប្រជុំព្រមគ្នា   ព្រះសង្ឃដែលនៅ
នៅក្នុងខណ្ឌដទៃ  ក៏ប្រជុំព្រមគ្នាក្នុងខណ្ឌនោះ ៗ  លុះព្រះពុទ្ធសាសនា
រុងរឿងមានព្រះសង្ឃច្រើនឡើង ក៏តោងបង្រួញខេត្តសីមាឲ្យតូចចុះ ដើម្បី
ស្រួលដល់ការប្រជុំ  ហេតុដល់ទៅកំណត់ខេត្តសីមាក្នុងវត្តមួយៗ  សាង
រោងឧបោសថជាទីធ្វើសង្ឃកម្មដូចនេះ  មួយយ៉ាងទៀតត្រូវឲ្យបសាងស្តូប
បញ្ចុះអដ្ឋិធាតុ  អ្នកទ្រទ្រង់គុណធម៌ក្នុងសាសនា  ទាំងបព្វជិតទាំងគ្រ-
ហស្ថ  វត្ថុបុរាណក្នុងប្រទេសនេះ  ដែលសាងក្នុងសម័យដំបូងទើបនឹង
កាន់លទ្ធិលង្កាវង្សក៏មានច្រើន  តាំងនៅស្រុកធំ ៗ និងស្រុកជារាជធានី
កប់តាំងពីខាងលើចុះមក  ដូចយ៉ាងមឿងជាងសែន  មឿងជាងរ៉ាយ
មឿងជាងម៉ៃ  មឿងសួគ៌លោក  មឿងសុខោទ័យ  មឿងកំផែងពេជ្រ

មឿងលពបុរី ព្រះនគរស្រីអយុធ្យា និងមឿងនគរស្រីធម្មរាជ អម្បាលនេះ ជាទីសម្គាល់ លក្ខណៈវត្តបុរាណដែលសាងក្នុងសម័យនេះ សង្កេតមើលទៅក៏មានលក្ខណជាមួយគ្នាយ៉ាងដើម គឺជាវត្តព្រះចេតិយ៍ ១ យ៉ាង ជាវត្តអនុស្សាវរីយ៍ ១ យ៉ាង វត្តខ្លះទើបមានរោងឧបោសថ តែធ្វើតូចៗ ធ្វើទុកនៅទីមួយអន្លើដែលមិនខាស់វែងវត្តសំខាន់ របស់វត្តមានតែព្រះស្តូបចេតិយ៍និងវិហារហ្លួង វត្តដូចបានពណ៌នាមកនេះ គប្បីឃើញជាតួយ៉ាងដ៏ល្អ សឹងមាននៅក្នុងវត្តព្រះហ្លួង មឿងស្វាន្គបុរី មានព្រះស្តូបចេតិយ៍តាំងនៅក្នុងរោងពាក់កណ្តាល ខាងមុខមានព្រះវិហារហ្លួងធំ ៩ ល្វែង តែឯរោងឧបោសថនោះ នៅសាងទុកនៅមុខកំផែងវត្តខាងក្រោយ ជារោងតូច មើលទៅព្រះសង្ឃនិងអង្គុយបំណុះត្រឹម ៧០ អង្គយ៉ាងច្រើន តាំងពីសម័យក្រុងសុខោទ័យជារាជធានីនោះឯង តមកសម័យក្រោយទើបធ្វើពង្រីករោងឧបោសថឲ្យធំឡើង ហើយកាន់ជារបស់សំខាន់ ១ យ៉ាង ក្នុងវត្ត សន្និដ្ឋានឃើញថា ព្រោះកើតមានអ្នកបួសរៀនច្រើនឡើង ញាតិញោមមានបំណងចង់ឃើញព្រះសង្ឃធ្វើឧបសម្បទកម្មឲ្យរីករាយចិត្តប្តូរយ៉ាងទៀត ព្រោះប្រពៃណីថ្វាយសំពត់កឋិនគេកាន់ជាកិច្ចសំខាន់ឡើង ដល់ទៅព្រះមហាក្សត្រិយ៍ស្តេចព្រះរាជដំណើរទៅថ្វាយកឋិន ដោយក្បួនហែ ដូចមានប្រាកដក្នុងសិលាចារឹករបស់ព្រះបាទរាមកំហែង អ្នកដែលសាងមិនជួសជុលវត្ត ទើបកាន់យកការសាងរោងឧបោសថជាការសំខាន់ធំដុំ

ឡើង មួយយ៉ាងទៀតនៅមានឲ្យសំខាន់ក្នុងការសាងវត្តក្នុងសម័យដែល ពោលនេះ គឺខាងពួកគ្រហស្ថមានសេចក្តីកប់អានថា ទីបញ្ចុះអដ្ឋិធាតុ របស់វង្សត្រកូលគួរសាងជាចេតិយ៍ វត្តឧទ្ទិសដល់ព្រះសាសនា វេលា អ្នកដើមត្រកូលមរណភាពបូជាសពហើយទើបច្រើនសាងព្រះស្តូប ហើយ បញ្ចុះចេតិយ៍តេជ្ជូបយ៉ាងតូចរូប ឬព្រះបរមធាតុទុកខាងលើ ខាងក្រោម ធ្វើជាគ្រឹះបញ្ចុះអដ្ឋិធាតុរបស់បុព្វការីបុគ្គល ដែលមរណភាពនោះ ទឹង អដ្ឋិធាតុរបស់អ្នកដែលតំណវង្សត្រកូលតមក ខាងមុខព្រះស្តូបសាងព្រះ វិហារមួយខ្នងទុកជាទីសម្រាប់ធ្វើបុណ្យ ទើបកើតមានវត្តអនុស្សាវរីយ៍ ឡើងជាច្រើន តាំងពីតូចរហូតដល់ធំ តាមកម្លាំងរបស់ត្រកូលដែលនឹង គប្បីសាងបាន បំណែកឯកជនត្រកូលៈនោះសាងវត្តធំៗ ទឹងសាងព្រះ ចេតិយ៍បញ្ចុះអដ្ឋិរៀងរាយនៅក្នុងវត្តនោះក៏មានដែលសាងជាវត្តក្រៅផ្សេង ក៏មានក្នុងជំពូកវត្តអនុស្សាវរីយ៍ សំដៅពាក្យមកដែលនៅក្នុងមឿងសុគតិ- លោកមឿងសុខោទ័យ គ្មានកើតនៅ [illegible] ទឹងគ្មានទីសម្រាប់ព្រះសង្ឃ នៅ។ ៩ សេចក្តីដែលពោលមកនេះ មានភស្តុតាងដែលគប្បីឃើញនៅទី កណ្តាល មឿងសុគតិលោក មានវត្តស្តូបធំៗ សាងទុកដល់ទៅ ៨ វត្ត មានវែងក្រៅដែលសាងទុកព្រះសង្ឃនៅតែវត្តមួយប៉ុណ្ណោះ វត្តតូចៗ ដែលសាងជាវត្តអនុស្សាវរីយ៍មាននៅរាយពាសពេញរាយៈត្បូងជាច្រើន សុទ្ធមាន តែព្រះចេតិយ៍ ១ អង្គ ទឹងវិហារ ១ ខ្នងទៀតគ្រប់វត្ត សេចក្តីដែលពោល

មកនេះជាពាក្យអធិប្បាយតែសង្ស័យក្នុងរឿងដែលថា ម្ដេចមនុស្សបុរាណទើបចូលចិត្តសាងវត្តច្រើនដល់ម្ល៉េះ ។

៨- មកដល់សម័យក្រុងស្រីអយុធ្យាជារាជធានី គតិកាន់ព្រះពុទ្ធ-សាសនា ក៏ដូចកាលក្រុងសុខោទ័យជាច្រើន មានវត្តស្ដេចដែលសំ-ខាន់ គឺវត្តព្រះស្រីសារពេជ្ញសាងឡើងក្នុងបរិវេណព្រះរាជវាំង ដូចវត្តមហាធាតុនៅមឿងសុខោទ័យ ជាទីបញ្ចុះអដ្ឋិធាតុក្សត្រិយ៍ផែនដីនិងព្រះរាជវង្សានុវង្សក្នុងរាជត្រកូល នៅមានវត្តដទៃទាំងរបស់ស្ដេចរបស់រាស្ត្រសាងទុកមកជាច្រើនណាស់ តែការសាងវត្តក្នុងសម័យក្រុងស្រីអយុធ្យាសង្កេតមើលឃើញថា ខុសគ្នានឹងបែបគ្រាក្រុងសុខោទ័យខ្លះ គឺ១យ៉ាងនោះ បណ្ដាវត្តទាំងតូច មើលទៅមានរោងឧបោសថជិតតែទាំងអស់ ព្រោះក្នុងសម័យក្រុងស្រីអយុធ្យាការបួសរៀនបានកាន់ជាប្រវេណីថា ប្រុសៗរាល់រូបត្រូវតែបួស នេះជាហេតុឲ្យមានព្រះសង្ឃច្រើនឡើងជាងពីដើមជាច្រើនភាគ ទើបត្រូវសាងរោងឧបោសថនិងកុដិសម្រាប់ព្រះសង្ឃនៅក្នុងវត្តជាច្រើន ១យ៉ាងទៀតនោះ ក្នុងរឿងបញ្ចុះអដ្ឋិធាតុរបស់វង្សត្រកូលច្រើនសាងជាព្រះស្តូបចេតិយ៍ រាយទៅក្នុងលានវត្តជំនួសបញ្ចុះរួមគ្នាក្នុងគ្រឹះ ក្រោមព្រះចេតិយ៍ធំយ៉ាងគ្រាក្រុងសុខោទ័យ ប្រការ៦ទៀតកាលមានប្រវេណីដែលបួសរៀនផ្សាយទូទៅ រមែងមានអ្នកបួសតែមួយគ្រាត្រឹម ១វស្សាប៉ុណ្ណោះដោយច្រើន កាន់យកឱកាសដែលចូលទៅបួសជាពេល

សម្រាប់រៀនសូត្រ ការរៀនសូត្រទើបចម្រើនឡើងតាមវត្ត ពាលីតែ អ្នកជាអាណាព្យាបាលរបស់ក្មេងច្រើននាំក្មេងទៅផ្ញើទុកឲ្យរៀនសូត្រ ទំនងដូចគ្នាទឹងពេងរៀនប្រជាបាលសព្វថ្ងៃនេះ ។

៩- មកដល់សម័យក្រុងរតនកោសិន្ទ្រ ក្នុងរឿងព្រះសាសនា ក៏កាន់តាមបែបក្រុងស្រីអយុធ្យាតមក តែមកមាន១សំខាន់ដែលផ្លាស់ប្តូរខ្លះ មានដើមថា ក្រុងរតនកោសិន្ទ្រសាងឡើងក្នុងសម័យដែលភូមាទំលាយលាងក្រុងស្រីអយុធ្យា ស្រុកទេសកើតចលាចល ទើបនឹងព្យាយាមមករាងសាងខ្លួនឡើងថ្មី បានឮថាលោកដែលជាបុព្វការីរបស់យើងទាំងឡាយ ប្រារព្ធដល់ភ័យន្តរាយដែលនឹងមានមកដល់ព្រះនគរ ក្នុងវេលាដែលនៅមិនទាន់តាំងមាំមួន ទើបឈប់ស្ទះប្រវេណីដែលបញ្ចុះអដ្ឋិក្នុងវត្ត ១ គ្រាសិន ច្រើនតែរក្សាអដ្ឋិវង្សត្រកូលទុកនៅផ្ទះរៀងខ្លួនជាប់ជាប្រវេណីរហូតដល់សព្វថ្ងៃនេះ ហេតុដែលនឹងសាងវត្តឡើងថ្មីក៏តិចចុះមិនសូវហ៊ានសាង ក្នុងរជ្ជកាលទី ១ ទ្រង់សាងវត្តថ្មីឡើងតែ ២ វត្ត គឺវត្តព្រះស្រីរតនសាស្តារាម សាងព្រមគ្នានឹងក្រុងរតនកោសិន្ទ្រវត្ត ១ ដល់មកចុងរជ្ជកាលទ្រង់ចាប់សាងវត្តសុទសន៍ ដើម្បីជាទីប្រតិស្ឋានព្រះពុទ្ធរូបអង្គធំ ដែលនិមន្តមកអំពីមឿងសុខោទ័យ វត្ត ១ ទៀតក្រៅអំពីនោះ បណ្តាទីទ្រង់សាងក្នុងរជ្ជកាលទី ១ ដូចយ៉ាងវត្តព្រះជេតពន វត្តស្រះកេស វត្តសុវណ្ណារាមជាដើម និងវត្តដែលមហាឧបរាជទ្រង់សាង ដូចយ៉ាងវត្តមហាធាតុ វត្តឈ្នះសង្គ្រាមជាដើមរហូតដល់វត្តពជបុរាណ ដែល

ទ្រង់ព្រះមេត្តាប្រោសឲ្យទៅហ្វាយក្រុមហ៊ុន ឆេពហារិកត្ត ទ្រង់សាងក៏ជាវត្តចាស់មានមកហើយ តាំងពីគ្រាក្រុងស្រីអយុធ្យាតាំងអស់ ៗ ដល់មករជ្ជកាលទី ២ ទ្រង់សាងវត្តអរុណ ក៏ជាវត្តចាស់ដែលមានមកហើយអំពីដើម ៗ ក្នុងរជ្ជកាលទី ៣ ព្រះបាទសម្តេចព្រះនាំងក្លៅ ទ្រង់ឈឺឆ្អាលក្នុងការសាងវត្តច្រើន ដោយមានព្រះរាជបំណង នឹងឲ្យក្រុងរតនកោសិន្ទ្ររុងរឿងយ៉ាងសម័យក្រុងស្រីអយុធ្យៈ ដែលច្រើនហៅក្នុងសម័យនោះថា គ្រាស្រុកទេសសាន្តត្រាណ តែកាលពិគ្រោះមើល ក៏ជាការបដិសំខរណ៍ជួសជុលវត្តចាស់ច្រើន ជាងដែលសាងឡើងថ្មី ក្នុងសម័យដែលសាងឡើងថ្មី ក្នុងសម័យតមកការសាងវត្តកាន់ថា ទាល់តែមានហេតុមែនៗ ទើបសាង ចំនួនវត្តក្នុងក្រុងរតនកោសិន្ទ្រ ទើបតិចជាងកាលជាន់អំពីដើម ៗ

១០- ការសាងវត្ត បើនឹងនិយាយតាមគតិដែលតែងកប់អានក្នុងវេលានេះ ទាំងរាជការនិងព្រះថេរសមាគម មានសេចក្តីឃើញត្រូវគ្នាថា ការដែលសាងវត្តឡើងថ្មីមានទាំងគុណទាំងទោស ដែលជាគុណនោះ ដូចយ៉ាងសាងឡើងក្នុងទីប្រជុំជនដែលមានផ្ទះសម្បែងច្រើន លើកតួយ៉ាងដូចនៅថែវព្រៃកវៀត ដែលមិនទាន់មានវត្ត បើសាងវត្តឡើងសុទ្ធតែជាគុណមួយយ៉ាង ព្រោះរាស្ត្រក្នុងទីនោះ នឹងបានប្រព្រឹត្តកិច្ចព្រះសាសនា ដូចយ៉ាងធ្វើបុណ្យឲ្យទានជាការកុសល នឹងកាន់សីលចម្រើនធម្មបដិបត្តិ ទាល់តែទៅសិក្សាស្ថានសម្រាប់កូនចៅរបស់រាស្ត្រ ក្នុង

តំបន់នោះ ។ តែបើសាងវត្តឡើងថ្មីក្នុងតំបន់ស្រុកដែលមានវត្តចាស់ពីដើមទៅ ហើយរមែងកើតទោសជាងឲ្យគុណ មានដើមថា ព្រះសង្ឃរមែងគោងអាស្រ័យចិញ្ចឹមជីវិតដោយបច្ច័យទាន ដែលអ្នកស្រុកក្នុងទីនោះចិញ្ចឹមមានវត្តតែមួយ បច្ច័យលាភល្មមធាន់គ្រប់គ្រាន់ ជាបើមានវត្ត ២ ធ្វើឲ្យលំបាកអត្តខាត់បន្តិចឡើង មួយស្ថានទៀតវត្តដែលសាងថ្មី អ្នកសាងសូម្បីជាសេដ្ឋីគហបតីមានទុនទេច្រើន អាចទំនុកបម្រុងរក្សាឲ្យរុងរឿងបាន តែកាលឥតអំពីម្ចាស់ដើមទៅហើយ កម្លាំងដែលទំនុកបម្រុងក៏ថយចុះដោយលំដាប់ធ្លាក់ទៅជាភារៈរបស់រាស្ត្រ អ្នកស្រុកក្នុងទីនោះកាលកម្លាំងមិនល្មមនឹងបម្រុងរក្សាច្រើនវត្តបាន ក៏គោងហោលវត្តខ្លះឲ្យបែកបាក់ទៅទទេជាទីបំផុត ដោយនេះអ្នកដែលសទ្ធាក្នុងការសាងវត្តជាព្រះសង្ឃក្តីគ្រហស្ថក្តី ទាំងក្នុងក្រុងទាំងក្នុងខេត្តក្រៅ ទើបច្រើនតែជួសជុលវត្តចាស់ដែលមានមកហើយ ជាងសាងឡើងជាថ្មីហើយមានទាំងព្រះរាជបញ្ញត្តិផងថា ការដែលនឹងសាងវត្តឡើងថ្មី លុះតែវត្តឯណាដែលសាងសមគួរដល់ភូមិប្រទេស ហើយគួរជឿបានថានឹងចម្រើនរុងរឿងតទៅបាន ទើបព្រះរាជទានទីវិសុង្គាមសីមា បើជាវត្តគ្រាន់តែជាសាងឡើង មិនបានជាមាំមួនទេ ឲ្យហៅថាសំណាក់សង្ឃ អាចនឹងមានឡើង ឬអាចនឹងរុះរើទៅវិញវេលាណាក៏បាន ដូចយ៉ាងផ្ទះរបស់រាស្ត្រ សេចក្តីបំណងដ៏ជាសាធារណៈក្នុងបច្ចុប្បន្ននេះ ទៅក្នុងផ្លូវខាងទំនុកបម្រុង

ការសិក្សាទីនប្រជោជធម៌វិន័យ ឲ្យរុងរឿងណាស់ឡើង ជាប្រយោជន៍ ទាំងខាងពុទ្ធចក្រនិងអាណាចក្រប្រកបគ្នា ដើម្បីឲ្យព្រះពុទ្ធសាសនាឋិតថេរចីរកាលជាអង្វែងតទៅ សឹងយើងទាំងឡាយ គួរឃើញថាជាកុសលោបាយ និងរដ្ឋាភិបាលនោបាយ ដ៏ប្រពៃយ៉ាងក្រៃពេក ។

# ប្រវត្តិ របស់ វត្តពោធិវាល

## ឃុំវត្តសង្កែ ខេត្តបាត់ដំបង

ចៅអធិការ អ៊ុីវ-ឡូត រៀបរៀង

(១)

---

## ពាក្យប្រារព្ធដើម

ដើមហេតុដែលនឹងកើតឡើងជាសៀវភៅនេះ គឺចៅអធិការ "អ៊ុីវ-ឡូត" កាលទើបនឹងបួសជាភិក្ខុបាន ៣ វស្សា មកគិតឃើញថា វត្តនីមួយៗ ដែលចាប់កសាងមកក្នុងរវាង ៦០ ឆ្នាំឬ ៧០ ប៉ុណ្ណោះ សួរដំណើរប្រវត្តិរបស់វត្តដែលនឹងសាង តើមានដំណើរហេតុអំពីដើមដូចម្តេចខ្លះ លោកមេវត្តតែប៉ុន្មានតមកហើយ ក៏មិនបានសេចក្តី ព្រោះនិយាយមិនចេះត្រូវគ្នា ទើបមកត្រិះរិះថា បើមានជាប្រវត្តិសម្រាប់វត្តទៅខាងមុខនឹងមានសេចក្តីចម្រើន គិតដូចនេះទើបសាកសួរពួកចាស់ៗ ដែលធ្លាប់នៅវត្តនេះពីក្មេងមក គឺលោកគ្រូព្រះឧបជ្ឈាយ៍ សម ១ លោកបណ្ឌិត ព្រម ជាគ្រូសូត្រនៅវត្តពោធិវាលពីដើមមកមួយ យាយ ឡាំ ជាភរិយាលោកបណ្ឌិត ព្រម ១ យាយ ម៉ែន ជាចៅលោកយាយ ពត លោកកូវាំង កែ ដែលជាអ្នកជួយផ្តើមគិតកសាងវត្តជាដំបូង ១ តាប្រាក់ ១ អ្នកទាំងនេះសុទ្ធតែមានអាយុតាំងអំពី ៨០ ឆ្នាំ ឡើងទៅសមសួរ អ្នកទាំង

អស់បានសេចក្ដីត្រូវគ្នា យកសេចក្ដីនោះមកធៀបនឹងពង្សាវតារក្រុងកម្ពុជា ហើយនឹងសាវតារបាត់ដំបង បានសេចក្ដីត្រូវគ្នាទើបកត់សេចក្ដីទុកមក តែមិនបានរៀបរៀងឲ្យជារបៀបព្រោះមិនមានឱកាស លុះដល់មកឆ្នាំជូតឆស័ក ពុទ្ធសករាជ ២៤៦៧ ត្រូវនឹងថ្ងៃ ៣ ខែដេសមឆ្នាំ ១៩២៤ មានបង្គាប់រាជការឲ្យធ្វើសាវតារពល់វត្ត ទើបរៀបរៀងជូនរាជការដោយបន្ទាន់ សេចក្ដីខ្ញុំមិនបានចប់សព្វគ្រប់ ដែលនឹងកើតរៀបរៀងជារបៀបដោយសព្វគ្រប់ក្នុងគ្រានេះ គឺកើតអំពីលោកម៉ាដឺម៉ូអាហ៊ែល ការ-ប៉ឺឡែស ជាចាងហ្វាងព្រះរាជបណ្ណាល័យកម្ពុជា អញ្ជើញមកមើលបុរាណវត្ថុក្នុងវិហារវត្តពោធិវាល មានសេចក្ដីពេញចិត្តចង់ឲ្យរៀបរៀងរឿងអ្វីនីមួយលោកនឹងបោះពុម្ព រើបយកសេចក្ដីដែលធ្វើសាវតារមិនទាន់សម្រេចនេះប្ដឹងលោក ៗ ក៏មានសេចក្ដីត្រេកអរបង្គាប់ឲ្យរៀបរៀងសាវតារ ហើយថតរូបបុរាណវត្ថុដាក់ នឹងសៀវភៅនេះ ជូនទៅព្រះរាជបណ្ណាល័យ លុះលោកចាងហ្វាងឲ្យឱកាសជួបនោះ ក៏ទទួលធ្វើតាមបង្គាប់ តែរូបថតនោះ មិនបានចាត់តាមរបៀបដែលតាំងក្នុងទូនោះទេ គ្រាន់តែជ្រើសរើសយករបស់ឯណា ឲ្យសមគួរយកមករៀបតាំង ឲ្យសមគួរយកមករៀបតាំងឡើត ហើយបានរៀបរៀងសាវតារក្នុងភាគ ១ សម្រេចនៅថ្ងៃអង្គារ ១៤ កើត ខែអស្សុជ ឆ្នាំថោះនព្វស័កពុទ្ធសករាជ ២៤៧០ ត្រូវនឹងថ្ងៃ ១១ ខែឧកតូបឆ្នាំ ១៩២៧ ។

# សាវតារ វត្តពោធិ៍វាល ឃុំវត្តសង្កែ ខេត្តបាត់ដំបង

សេចក្តីដើមដែលនឹងកសាងវត្តពោធិវាលនេះ នៅខែពិសាខ ឆ្នាំខាលសំរិទ្ធិស័ក ពុទ្ធសករាជ ២៣៦១ គ្រិស្តសករាជ ១៨១៨ រាជការក្រុងកម្ពុជាក្នុងរាជសម្តេចព្រះឧទ័យរាជាធិរាជម្ចាស់អង្គចន្ទ រាជការស្រុកសៀមក្នុងរាជព្រះឡឹតឡានកាលៃស្រុកបាត់ដំបង ហៅហ្វាយស្រុកទី ៣ គឺលោកអភ័យទីបេស រស់ កាលកសាងវត្តពោធិវាលនេះ លោកអភ័យទីបេស រស់ ធ្វើហៅហ្វាយស្រុកបាត់ដំបងបាន ២ ឆ្នាំ ដំណើរសេចក្តីដើមដែលនឹងប្រារព្ធធ្វើវត្តពោធិវាលនេះ គឺទីដីវត្តជាទួលមានស្រែជុំវិញ មានពោធិមួយដើមធំនៅខាងលិចទួល ពោធិនោះដើមចាស់មនុស្សក្នុងគ្រានោះគ្មានអ្នកណាកើតទាន់ មិនដឹងពីកាលណាមក ហៅថាទួលពោធិវាលនេះ តៗគ្នាមក ឯដីស្រែទួលពោធិវាលនេះជារបស់លោកគុជ្ឈស័ក្យ សួរ ហេតុដែលនឹងកសាងវត្តនោះ គឺលោកកូវាំង កែ លោកយាយ ពត គាត់ធ្វើស្រែខាងត្បូងទួល វេលាអាធ្រាត្រស្ងាត់ អ្នកបញ្ញាន់ស្រូវក្រឡេកមើលមកឃើញ ដូចជាមានពន្លឺកណ្តាលទួលពល់ពគ្រី ទើបអ្នកបញ្ញាន់ស្រូវយកសេចក្តីនេះ ជម្រាបយាយពត ១ ក៏បានសង្កេតមើលឃើញប្លែកដូចនោះ ទើបយកសេចក្តីនេះទៅជម្រាបលោកគុជ្ឈស័ក្យតាមដំណើរ ។

លុះវេលាអាធ្រាត្រស្ងាត់ លោកគុជ្ឈស័ក្យទៅសង្កេតមើលឃើញសមដូចពាក្យលោកកូវាំង កែ យាយ ពត លុះព្រឹកឡើងលោកគុជ្ឈស័ក្យឲ្យខ្ញុំប្រុសយកចបទៅជីកកណ្តាលទួលប្រទះអិដ្ឋជីកចុះទៅប្រមាណ ២ ហត្ថ

ប្រទះថ្មជាមួយបន្ទះ គាស់ថ្មឡើងឃើញថ្មមូលទទឹងបាតប្រហែល ១០ ធ្នាប់ កំពស់ជាង ១ ហត្ថ អ្នកទាំងនោះប្រមាណថាសទ្ទឹកសីមា ជីកចុះបន្តិចទៅទៀតឃើញព្រះពុទ្ធរូប ហើយមានថ្មទ្រាប់ពីក្រោម ទើបលោកគុជ្ជ-ស័ក្យឲ្យលើកព្រះនឹងសទ្ទឹកសីមាឡើងមកលើ ហើយឲ្យជីកចុះទៅទៀត ពុំឃើញមានអ្វី លោកគុជ្ជស័ក្យឲ្យឈប់ជីក យកព្រះនិងសទ្ទឹកសីមា លាងជូតស្អាតល្អ ហើយតម្កល់ទុកនៅទីកន្លែងជាសមគួរ ទើបលោកគុជ្ជ-ស័ក្យឲ្យទៅអញ្ជើញលោកគ្រូកាំង [illegible]ក លោកឃាយ ពក មកពិគ្រោះថា ទីដីទួលពោធិ៍លនេះ ប្រហែលជាកន្លែងវត្តពីបុរាណហើយសាបសូន្យទៅបើដូចនេះ យើងនឹងគិតកសាងវត្តនៅទួលពោធិ៍លនេះ លោកទិមន្តលោកគ្រូ គុជ លោកគ្រូ ស៊ុំ មកគង់ ៗ នឹងពណ៌នាអំពីលោកគ្រូគុជ លោកគ្រូ ស៊ុំ កាលដើមលោកគង់នៅវត្តពោធិ៍កុង មិនបានជាមេវត្តទេ លោកទាំងពីរអង្គនេះ ជាអ្នកប្រព្រឹត្តធម៌វិន័យ លោករក្សាក្រមមូលធុតង្គ វេលាចូលវស្សាលោកមកចូលនៅវត្តពោធិ៍ ដល់ខែប្រាំងចេញទៅក្រមមូល ពួកអន្តេវាសិកលោកមានប៉ុន្មាន ក៏តាមទៅក្រមមូល ហើយលោកកាន់តេចីវ-រិកធុតង្គជានិច្ច គឺមិនប្រើចីវរឲ្យលើសអំពីបី ទាំងរូបិយទៀត លោកក៏មិនទទួលកាន់ដោយដៃខ្លួនឯង លុះឯក្រោយមកលោកមេវត្តនោះសិក្ខទៅ ពួក

ឧបាសកឧបាសិកានិមន្តលោកគ្រូ គុជ ឲ្យធ្វើមេវត្ត(១) លោកគ្រូ គុជ មិនព្រមទទួល និមន្តលោកគ្រូ ស៊ីវ ក៏មិនព្រមទទួល ថាដ្បិតលោកមិនបាននៅជានិច្ច ដែលអាស្រ័យនៅតែក្នុងព្រះវស្សា បើលោកអង្គណាធ្វើ លោកក៏ជ្រកកោនផងសូមតែសេចក្ដីសុខ ទើបពួកទាយកនិមន្តលោកដែលមានវស្សា ជាអណ្ដាប់ចុះមកឲ្យធ្វើមេវត្តលុះលោកមេវត្តថ្មីបានធ្វើជាមេអាវាសឡើង ក៏តាំងប្រព្រឹត្តអនាចារផ្សេងៗ ធ្វើពេទ្យមើលជម្ងឺ ធ្វើហោរ លោកអណ្ដាប់ខ្ទះហាត់ប្រដាល់ ទាត់សី បង្ហើរខ្លែង លេងចត្រង្គ ខាងពួកលោកគ្រូ គុជ លោកគ្រូ ស៊ីវ ឃើញវិប្បរិតដូចនោះ ក៏មានសេចក្ដីក្តៀសចិត្ត មិនបានធ្វើសង្ឃកម្មជាមួយផងក្នុងគ្រានោះទើបបែកជាពីរពួក ទើបលោកជាធំខាងរាជការ មកគិតចែកដីវត្តតាមតែស្ម័គ្រ គឺអំពីអ្នកតាពាំងមកទល់របងខាងជើង សម្រេចខាងលោកមេវត្ត អំពីអ្នកតាពាំងមកទល់របងខាងត្បូង សម្រេចខាងពួកលោកគ្រូ គុជ លោកគ្រូ ស៊ីវ ធ្វើឧបោសថកម្មមួយសីលពួកលោកមេវត្ត មួយសីលពួកលោកគ្រូ គុជ មិនធ្វើរួមគ្នា ផ្លាស់គ្នាជាដរាបហើយចាត់ឲ្យគ្រងកឋិនមួយឆ្នាំមួយអង្គ ៗ

តែខាងលោកគ្រូ គុជ លោកគ្រូ ស៊ីវ មិនទទួលគ្រង ដំណើរផ្លូវ

១-កាលបុរាណពីដើមគ្មានតាំងចៅអធិការទេ ស្រេចតែនឹងពួកជើងវត្តយល់ព្រមអង្គណាក៏និមន្តព្រះថេរដែលជាអធិបតីក្នុងសង្ឃ១អង្គមក ហើយក៏និមន្តលោកដែលយល់ព្រមនោះ ឲ្យធ្វើមេវត្តព្រះថេរដែលជាអធិបតីកំប្រឹតល់អាវាស ព្រមទាំងធរណីសង្ឃនូវរបស់គរុភណ្ឌឲ្យហើយ ព្រះថេរព្រមទាំងជំនុំសង្ឃក្នុងអាវាសក៏ស្ម័គ្រជយន្តោឲ្យជាការស្រេចហើយក៏នាំគ្នាហៅលោកគ្រូមេវត្តខ្លះ លោកគ្រូសង្ឃរាជខ្លះ បានជាពាក្យហៅលោកសង្ឃរាជនេះជាប់មកដល់ឥឡូវនេះ ៗ

ប្រតិបត្តិខាងពួកលោកគ្រូ គុជ ល្អច្រើនប្រការ ទើបជាទីជ្រះថ្លាដល់លោក គុជ្ជស័ក្យ ព្រមទាំងសាសនិកជនដែលស្រឡាញ់ធម៌ពិត ។

ឯខាងលោកគុជ្ជស័ក្យ លុះពិគ្រោះនឹងកូនាំង "កៃ" យាយ "ពត" ព្រមទាំងសាច់ញាតិជិតខាងក៏សោមនស្សយល់ព្រមផង ទើបលោកគុជ្ជ-ស័ក្យចូលទៅសូមអនុញ្ញាតលោកអភ័យទីបេស "សេ" ជាចៅហ្វាយ-ស្រុកបាត់ដំបង លោកអភ័យទីបេស "សេ" ក៏ព្រមអនុញ្ញាត ហើយមានសទ្ធាបានជួយធនទ្រព្យមកទឹងលោក គុជ្ជស័ក្យផង ។ លោកគុជ្ជស័ក្យក៏កាន់តែមានសេចក្ដីត្រេកអរ ត្រឡប់មកបាត់ចែងឃោសនាបានគ្នាច្រើនទៅច្រាប់ដីទួលនោះ កំណត់ធ្វើជាឧបចារ ក្រសទទឹង ១២៥ ម៉ែត្រ បណ្ដោយ ១៩១ ម៉ែត្រ លុះច្រាបបានរាបល្អរកឈើអិដ្ឋកំបោរបានស្រេច តាំងលើកព្រះវិហារ ហើយធ្វើសាលាកុដិជាបណ្ដើរ ជីកស្រះមួយក្បែរសាន វត្តសម្រាប់ព្រះភិក្ខុសង្ឃស្រង់ឆាន់ ។

លុះចាត់ព្រះអារាមបានល្មមសមគួរ ទើបប្រជុំពួកអ្នកដែលសទ្ធាប៉ុន្មាន ព្រមព្រៀមគ្នាទៅនិមន្តលោកគ្រូ "ស៊ុរ" ព្រមទាំងសិស្សលោកផងជា ១២ អង្គ ចូលមកគង់ក្នុងវត្តពោធិវាល លុះចាត់ធ្វើព្រះវិហារជាស្រេច ទើបលោកអភ័យទីបេស "សេ" អញ្ជើញមកប្រជុំព្រះភិក្ខុសង្ឃព្រមទាំងឧបាសកឧបាសិកា មានលោកគុជ្ជស័ក្យជាមគ្គនាយក ចាត់ចែងការតាំងបញ្ចុះសីមាក្នុងខែចេត្រ ឆ្នាំរោងទោស័ក ពុទ្ធសករាជ ២៣៦៣ លុះបញ្ចុះសីមាស្រេច ទើបវេរព្រះវិហារ សាលា កុដិ ព្រមទាំងបរិវេណឧបចារចំពោះដល់

ព្រះតេនត្រៃ ហើយតាំងលោកគ្រូ "គុជ" ជាមេវត្ត ជាព្រះឧបជ្ឈាយ៍ លោកគ្រូ "ស៊ីវ" ធ្វើជាគ្រូសូត្រ ហើយលោកគុជស័ក្យនិងលោកកូពាំង កែ យាយ ពត ក៏ថ្វាយខ្លួនជាញោមឧបដ្ឋាក ទំនុកបម្រុងវត្ត តរៀង មក ឯលោកគ្រូ គុជ លោកគ្រូ ស៊ីវ ព្រមទាំងអន្តេវាសិកប៉ុន្មានអង្គ ក៏តាំងសេចក្ដីសាមគ្គីចំប្រព្រឹត្តធម៌វិន័យ ផ្លូវឯណាដែលលោកធ្លាប់ប្រព្រឹត្ត មកមានរុក្ខមូលជាដើម លោកក៏មិនលះបង់ តែមិនបានទៅទាំងអស់ ផ្លាស់វេនគ្នាទៅខ្លះនៅចាំវត្តខ្លះ លោកដែលទៅត្រឡប់មក លោកនៅ ចាំវត្តចេញទៅរុក្ខមូលលោកគ្រូ គុជ មកគង់វត្តពោធិវាល បានប្រមាណ ៣ ឆ្នាំឬ ៤ ឆ្នាំ កើតរោគក្អកហឹតលោកឈប់រុក្ខមូលនៅប្រតិបត្តិតែក្នុងវត្ត ព្រោះអង្គលោកក៏កាន់តែចាស់ កាលលោកទទួលមរណភាពអាយុប៉ុន្មាន មិនប្រាកដ សួរបានសេចក្ដីថាវេង ៧០ ឆ្ងាយ លុះអត់អំពីលោកគ្រូ គុជ ទៅបានលោកគ្រូ ស៊ីវ ជាមេវត្តជាព្រះឧបជ្ឈាយ៍តមក លោកគ្រូ ស៊ីវ ក៏ឧស្សាហ៍ប្រតិបត្តិតាមគន្លងធម៌វិន័យ ដែលធ្លាប់ប្រតិបត្តិនឹងលោកគ្រូ គុជ មក តែផ្លូវរុក្ខមូលដាច់ ត្បិតអង្គលោកក៏ចាស់ តាមសេចក្ដីដែលបានសាកសួរចាស់ៗ អំពីអាយុលោកគ្រូ ស៊ីវ ដោយប្រ.មាណថាប្អូនលោកគ្រូ គុជ វេង ៧ ឆ្នាំឬ ៨ ឆ្នាំ លោកទាំងពីរអង្គនេះ មានសេចក្ដីសាមគ្គីរាប់អានគ្នា ដោយស្មោះត្រង់ លុះលោកគ្រូ ស៊ីវ អាយុ ៧៩ ឆ្នាំ ក៏ទទួលអនិច្ចធម្មទៅដោយរោគអ្វីមិនប្រាកដ លុះលោកគ្រូ ស៊ីវ អនិច្ចធម្មទៅបានលោកគ្រូ ទិត ជាសិស្សជាមេវត្ត លោក

គ្រូ ទិត ក៏ឧស្សាហ៍ប្រតិបត្តិទំនុកបំរុងវត្ត ឲ្យបានរុងរឿងគ្រប់ប្រការ លោកគ្រូ ទិត ធ្វើមេវត្តមិនយូរប៉ុន្មាន លោកបិត្តុជាយកភេសចូលទៅធ្វើកងការ ទទួលទីជាហ្លួងវិសេសសាលីជាអ្នកគេក្បាយ៉ាំង ឯវត្តពោធិ៍ពលបានលោកគ្រូ អ៊ិន ជាមេវត្ត លោកគ្រូ អ៊ីន ធ្វើមិនបានយូរប៉ុន្មាន ខូចចរិតរត់ទៅស្រុកលើ បណ្ដាសិស្សទៅតាមយកមកវិញ ឲ្យសិក្ខចេញជាយកភេស ទើបនិមន្តលោកគ្រូ នៃ ជាមេវត្តលោកគ្រូ នៃ នៅមិនយូរប៉ុន្មានក៏សិក្ខទៅទៀត បានលោកគ្រូ ចន្ទ ក៏តាំងព្រះទ័យឈឺឆ្អាល ទំនុកបំរុងវត្តឲ្យបានរៀបរយ ព្រោះកាលមេវត្តមុនទាំង ៣ គឺលោកគ្រូ ទិត-អ៊ិន-នៃ ធ្វើមិនបានប៉ុន្មានសិក្ខ បណ្ដាសិស្ស ក៏បែកទៅវត្តដទៃជាច្រើនពួក អ្នកដែលមានសទ្ធាធ្វើបុណ្យ ក៏បែកទៅវត្តឯទៀតខ្លះទៅ វត្តពោធិ៍ពលក្នុងគ្រានោះក៏រៀវរេយ លុះលោកគ្រូ ចន្ទ ធ្វើមេវត្តយូរបន្តិចសិស្សក៏កាន់តែមានច្រើនគ្រាន់ ពួកទាយកទាយិកា ក៏កាន់តែចុះចូលមកវិញ មានទាយកម្នាក់ឈ្មោះតា អ៊ិន យាយ លូក នៅភូមិអូរមី តែងមកធ្វើបុណ្យឯវត្តពោធិ៍ពល ដល់គាត់មានជម្ងឺធ្ងន់ ផ្តាំនឹងកូនថា ស្រែមួយតម្បន់និងអូរមីនេះចំនួនស្រែ ៤ បើអត់អំពីគាត់ទៅហើយ ឲ្យប្រគេនសម្រាប់វត្តពោធិ៍ពល លុះគាត់ទទួលអនិច្ចកម្មទៅ នាយ អាំ នាង ដែង ជាកូនបានប្រគេនដីស្រែនោះដល់លោកគ្រូ ចន្ទ ជាមេវត្ត ស្រែនោះក៏ជាស្រែសម្រាប់វត្តមក គ្រានោះព្រះវិហារអំពីលោកគុជ្ជស័ក្សសាងនោះ ចាស់គ្រាំគ្រា ទើបដង្ហៅ សៀង យាយ ម៉ា

មានសទ្ធាបង់សាងថ្មី បណ្ដាពួកទាយកទាយិកា ក៏មានសទ្ធាបូលវត្ត បច្ច័យតាមមានខ្សត់ធនទ្រព្យ ខ្លះខាតប៉ុន្មានដងឡើង សៀង យាយ ម៉ា ទទួលលើខ្លួនទាំងអស់ លុះចាត់គេគ្រៀងប្រដាប់បានលើកព្រះវិហារ នៅថ្ងៃ ៧ កើត ខែពិសាខ ឆ្នាំវកសំរិទ្ធិស័កពុទ្ធសករាជ ២៣៩១ កាលធ្វើព្រះវិហារនេះក្នុងពងការទើ ៦ គឺលោកអភ័យទិបេស នង ជាចៅហ្វាយស្រុកបាត់ដំបង លុះដល់មកថ្ងៃ ១៣ កើត ខែចេត្រ ឆ្នាំពទោស័ក លោកយាយ ម៉ា ចាត់សាងព្រះដីរធំ តាពជមន្ទៀន ស៊ូរ ជាជាង លុះដល់មកឆ្នាំកុរព្រះវិហារនិងព្រះពុទ្ធរូបអង្គធំ (ព្រះដិរ) ជាងធ្វើជាស្ទូរេច ទើបលោកយាយ ម៉ា ព្រមទាំងទាយកទាយិកាធ្វើបុណ្យឆ្លងព្រះវិហារនិងព្រះពុទ្ធរូប ឯព្រះវិហារដែលលោកយាយ ម៉ា សាងនោះ មុខជាប់ប្រក់ក្បឿង ដញ្ញាំងរៀបអិដ្ឋ លាបកំបោរ ហៅជាងក្បាច់ក្ប៊ូរក្បូនកណ្ដាលរូបទេពប្រណម្យជញ្ជ្យូ ដងក្ដារបិទមាស ប្រដាប់កញ្ចក់ កំផែងរៀបអិដ្ឋលាបកំបោរ ហើយលោកយាយ ម៉ា បានប្រគេនដីដាក់ទីងព្រំបងឯលិចវត្ត ទទឹង ៤៦ ម៉ែត្រ បណ្ដោយ ៦០ ម៉ែត្រ ប្រគេនដីជាប់ទីងព្រំរបងឯកើតវត្ត ទទឹង ១៨ ម៉ែត្រ ករណ្ដាយ ១៤០ ម៉ែត្រ ប្រគេនស្រែឯត្បូងវត្តមួយតម្បន់ចំនួនស្រែ ៤ ជាសម្រាប់វត្ត តា សៅ តា កែ គាត់ប្រគេនស្រែពីរនៅភូមិប្រាបពល ជាសម្រាប់វត្តពោធិពល ព្រមទិងលោកយាយ ម៉ា ទើបលោកយាយ ម៉ា ក៏ថ្វាយខ្លួនជាញោមឧបដ្ឋាកទំនុកបំរុងវត្តរៀងមក ក្នុងគ្រានោះ មានភិក្ខុ ២ អង្គ ឈ្មោះភិក្ខុ ដោក

ភិក្ខុ ចន្ទ លោកទាំង ២ អង្គនេះ តាំងពីព្យាយាមរៀនព្រះត្រៃបិដក ដោយការមាំមួន លោកគ្រូក៏មានសេចក្ដីពេញព្រះទ័យចង់ឲ្យរេះជាធាប់ ទើបនិយាយនឹងលោកទាំង ២ អង្គឲ្យចូលទៅរៀនឯស្រុកសៀម ត្បិតមានអ្នកប្រាជ្ញច្រើន លោកទាំង ២ អង្គ ក៏មានសេចក្ដីត្រេកអរយល់ព្រមផង ទើបលោកគ្រូ ចន្ទ ក៏ជូនលោកទាំង ២ អង្គ ទៅរៀនស្រុកសៀម ។

លុះដល់មក ឆ្នាំម្សាញ់នព្វស័ក ពុទ្ធសករាជ ២៤០០ ឆ្នាំលោកគ្រូ ចន្ទ ទៅទទួលលោកគ្រូអាចារ្យ ដោក ព្រមទាំងលោកអាចារ្យ ចន្ទ អំពីស្រុកសៀមចូលមកនៅក្នុងវត្តពោធិវាលវិញ ហើយលោកគ្រូ ចន្ទ ក៏ប្រគល់សិស្សទាំងប៉ុន្មានឲ្យលោកអាចារ្យ ដោក លោកអាចារ្យ ចន្ទ បង្ហាត់ច្រៀន ឯអង្គលោកគ្រូ ចន្ទ គេនិមន្តឲ្យធ្វើជាព្រះឧបជ្ឈាយ៍តមក ។

លោកអាចារ្យ ដោក និងលោកអាចារ្យ ចន្ទ ក៏តាំងបង្ហាញព្រះត្រៃបិដកភិក្ខុ សាមណេរ ក្នុងវត្តជារាល់ថ្ងៃ តែសាស្ត្រាបាលីក្នុងវត្ត-ពោធិវាលមានតិចណាស់ ទើបលោកអភ័យទ៉ែបេប ទន ជាចៅហ្វាយស្រុកបាត់ដំបងបានជ្រាបថា ភិក្ខុសាមណេរខាត់ ខាលសាស្ត្រាបាលីនឹងរៀនដូចនោះ ក៏បង្កើតសទ្ធាជ្រះថ្លាបរិច្ចាគទ្រព្យរបស់លោកផង លោកយាយ ម៉ា ផង ពួកទាយកទាយិកាសទ្ធាចូលរួមគ្នាផង បានធន-ទ្រព្យជាច្រើន ទើបនិមន្តលោកអាចារ្យ ដោក ឲ្យទៅជាវព្រះត្រៃបិដក និងទូ ហើយចាត់មន្ត្រីឲ្យនាំ ដំរី និងប្រាក់ទៅតាមលោកអាចារ្យ ដោក ឯស្រុកសៀម លោកអាចារ្យ ដោក ទៅជាវគម្ពីរនិងទូបានស្រេច ក៏

ចាត់ចែងគម្ពីរទាំងទូដាក់លើដំរី នាំចូលមកក្នុងស្រុកបាត់ដំបងយកទៅ
តម្កល់ក្នុងវត្តពោធិវាល ឯគម្ពីរដែលលោកអាចារ្យ ដោក នាំមកអំពី
ស្រុកសៀមទាំងប៉ុន្មាន ដូចមានក្នុងបញ្ជីសម្រាប់វត្តផ្សេងៗ ។

លុះគម្ពីរចូលមកដល់លោកអភ័យទីបេស នង ក៏មានសេចក្ដីត្រេក
អរជាយ៉ាងក្រៃពេក ទើបប្រជុំព្រះភិក្ខុសង្ឃក្នុងអារាម ព្រមទាំងលោក
យាយ ម៉ា ជាឧបដ្ឋាកវត្ត និងទាយកទាយិកាទាំងអស់គ្នា ហើយលោក
អភ័យទីបេសមានប្រសាសន៍កណ្ដាលជំនុំថា ឥឡូវនេះព្រះត្រៃបិដក និងទូ
ក៏បានព្រមដូចសេចក្ដីប្រាថ្នារបស់យើងពល់គ្នា តែមកនៅខាតតែទី
កន្លែងទីតម្កល់ព្រះត្រៃបិដកឲ្យសមគួរ បើដូចនោះគួរយើងទាំងសាមគ្គី
ព្រមគ្នាចេញទ្រព្យតាមសទ្ធាពល់ខ្លួន បើខ្វះខាតប៉ុន្មានលោកនឹងទទួល
ចេញទាំងអស់ ឲ្យតែបានសម្រេចក្នុងការសាងមណ្ឌបតម្កល់ព្រះត្រៃបិដក
ដើម្បីរះអាយុព្រះពុទ្ធសាសនាឲ្យបានឋិតថេរទៅខាងមុខ ។

ឯពួកជំនុំទាំងអស់គ្នាបានឮលោកអភ័យទីបេស មានប្រសាសន៍ដូច
នោះ ក៏មានសទ្ធាព្រមព្រៀង លោកអភ័យទីបេស នង ក៏ប្រគល់ធុរៈ
ឲ្យលោកអាចារ្យ ដោក ជាអ្នកត្រួតការលោក ក៏ចាត់ចែងរកជាងរក
គ្រឿងប្រដាប់ ឥដ្ឋ និង កំបោរ ហើយលើកដី កត្រឹះធ្វើជាកសិណ
ស្នាមក្បោះជុំវិញ នៅទីខាងលិចវិហារ លុះប្រុងគ្រឿងប្រដាប់បានព្រមតាំង
លើកមណ្ឌបនៅថ្ងៃ ១៣ កើតខែផល្គុណឆ្នាំមមីសំរិទ្ធិស័ក ពុទ្ធសករាជ
២៤០១ ឯមណ្ឌបនោះធ្វើមុខ ៤ ជញ្ជាំងឥដ្ឋកំពូលប្រាង្គណ៍សារពើសូត

លុះចាត់ធ្វើមណ្ឌបជាស្រេច ទើបលោកអភ័យទីបេស នង និងលោកយាយ ម៉ា ព្រមទាំងតាយកតាយិកាចាត់ការទូងស្រេចហើយដង្ហែព្រះត្រៃបិដកចូលទៅតម្កល់ក្នុងមណ្ឌប នៅឆ្នាំរកាទោស័ក ពុទ្ធសករាជ ២៤០៣ លោកអាចារ្យ ដោក និងលោកអាចារ្យ ចន្ទ ក៏នៅរក្សាព្រះត្រៃបិដកបង្ហាញភិក្ខុសាមណេរតមក គ្រានោះមានភិក្ខុមួយអង្គ ឈ្មោះឈឺនជាសិស្សលោកអាចារ្យ ដោក លោកភិក្ខុ ឈឺន ជាអ្នកមានព្យាយាមទាំងសតិបញ្ញាក៏ខ្លាស់ ទើបអាចារ្យ ដោក បញ្ជូនឲ្យទៅរៀនឯស្រុកសៀម លោកអាចារ្យ ដោក អង្គនេះ លោកយកព្រះទ័យឈឺផ្អាលក្នុងការថែទាំព្រះអារាម ហើយលោកឧស្សាហ៍បង្ហាញព្រះត្រៃបិដក បណ្ដាអ្នកពងការឬប្រជានុរាស្ត្រ ក៏រាប់អានលោកជាច្រើន ត្បិតលោកចេះក៏ច្រើន ទាំងទេសនាក៏ពីរោះ មានកេរ្ដិ៍ឈ្មោះ លុះមកដល់សព្វថ្ងៃ តែមើលទៅអធ្យាស្រ័យចិត្តលោក ហាក់ដូចជាមិនបង្អោនទៅតាមធម៌វិន័យ ច្រើនបង្អោនធម៌វិន័យមកតាមចិត្ត ត្បិតផ្លូវប្រតិបត្តិខាងធម៌វិន័យដែលគេធ្លាប់ប្រតិបត្តិតាំងអំពីលោកគ្រូ គុជ មក ដូចជាយ៉ាងរូបិយគេមិនធ្លាប់ទទួលទុកដាក់ដៃឯងមកអំពីលោកគ្រូ គុជ រហូតមកដល់លោកគ្រូឧបជ្ឈាយ៍ ចន្ទ លុះដល់អាចារ្យ ដោក មកពីស្រុកសៀមវិញ លោកដឹកនាំភិក្ខុសង្ឃទាំងអស់ថា ឲ្យទទួលរូបិយប្រើប្រាស់តាមធម្មតាទៅ កុំឲ្យវត្តដទៃគេរង្កៀសចិត្ត មួយទៀតសង្ឃលាភដែលគួរដល់ភិក្ខុដទៃ លោកក៏បង្អោនសង្ឃលាភនោះមកដើម្បីខ្លួនក៏មានលោកគ្រូឧបជ្ឈាយ៍ ចន្ទ លោកមានសេចក្ដីរាប់អាន លោកអាចារ្យ ដោក

ជួយទំនុកបម្រុងតាំងពីមិនទាន់ចេះព្រះត្រៃបិដក លុះដល់ចេះបានជាអាចារ្យ កាលពីដើមលោកទាំង ២ អង្គសាមគ្គីនឹងគ្នាដោយការស្និទ្ធ ។

លុះដល់លោកអាចារ្យ ជោក បានជាអាចារ្យ អ្នកមុខអ្នកការ គេកាន់តែគប់រកច្រើនឡើង ព្រះទ័យលោក ក៏បែកអំពីលោកឧបជ្ឈាយ៍ ចន្ទ ទៅជាស្គៀសនឹងគ្នា ដើមដែលកើតស្គៀសខ្លាំងនោះ គឺជួរកឋិនលោកអាចារ្យ ជោក ហៅគ្រូសូត្រកឋិនទៅនិយាយថា ទាយកជាម្ចាស់កឋិននោះ គេគប់រកខ្ញុំគេចង់ឲ្យខ្ញុំក្រង់ ហេតុនេះលោកគួរអប្ប-លោកន៍បង្វែរមកឲ្យខ្ញុំ គ្រូសូត្រទាំង ២ អង្គ ជាសិស្សរៀនព្រះត្រៃបិដកនឹងលោកអាចារ្យ ជោក នឹងមិនធ្វើតាមបង្គាប់ក្រង់ទាស់អធ្យាស្រ័យ ។

លុះដល់ថ្ងៃគេហែកឋិនមកលោកឧបជ្ឈាយ៍ ចន្ទ ក៏ចូលទៅអង្គុយកណ្ដាលជំនុំសង្ឃតាមរបៀប ដោយការមិនដឹងខ្លួនស្រាប់តែលោកគ្រូសូត្រអប្បលោកន៍ ក៏ឆ្លើយទៅលោកអាចារ្យ ជោក លោកឧបជ្ឈាយ៍ ចន្ទ ក៏ក្រោកអំពីកន្ទេលនោះថយមកក្រោយលោកស្ងៀមមិនថាអ្វី លោកអាចារ្យ ជោក ក៏ចូលទៅក្រង់កឋិន លុះសូត្រចប់កិច្ចកឋិន ជំនុំសង្ឃក៏ថយទៅកុដិវិញកល់ខ្លួន ទើបលោកគ្រូឧបជ្ឈាយ៍ ចន្ទ ក៏និមន្តគ្រូសូត្រ ប្រាំជាសិស្សច្បងព្រមទាំងបណ្ដាភិក្ខុជាសិស្សប៉ុន្មានអង្គមកជុំ ទើបប្រកាសប្រាប់ពល់អង្គថាខ្ញុំមានសេចក្ដីខ្មាសគេណាស់ បើលោកអាចារ្យត្រូវការក្រង់កឋិនក៏គួរតែប្រាប់ខ្ញុំឲ្យដឹង បើខ្ញុំមិនឲ្យក្រង់ក៏គួរធ្វើតាមអធ្យាស្រ័យរបស់ខ្លួនចុះ ។

ហេតុនេះលោកទាំងអស់អង្គ នៅផ្ញើខ្លួនទីងលោកអាចារ្យ ដោក ចុះ ខំសិក្សារៀនសូត្រទៅចុះ ផ្តាំតែប៉ុណ្ណេះ លោកក៏ហៅក្មេងពីរនាក់ ស្ពាយបរិក្ខារសម្រាប់ខ្លួន គឺបាត្រនិងសង្ឃាដី ហើយនិមន្តទៅគង់ឯវត្ត សុរកី គ្រានោះពួកបណ្ដាសិស្សព្រមទាំងអ្នកដើងវត្តក៏ផ្អើលពល់គ្នា បបួលគ្នាទៅនិមន្តលោកមក លោកក៏មិនព្រមមក នៅទីងវត្តសុរកីជាយូរខែ ។

លុះឯក្រោយ លោកអាចារ្យដោក ទទួលកំប៉ខុស អង្វរសូមទោសដោយប្រការផ្សេងៗលោកក៏ព្រមនិមន្តមកគង់នៅវត្តពោធិពល ពួកទាយកទាយិកា ក៏ប្រជុំព្រមគ្នាមកនិយាយសម្រួលលោកគ្រូទាំងពីរអង្គ ក៏តាំងព្រះទ័យសាមគ្គីនឹងគ្នាតរៀងមក ។

ឯលោកអាចារ្យ ចន្ទ ពួកសាច់ញាតិលោក ទទួលទៅកោះសុទិន ទៅ ព្រោះជាស្រុកកំណើតរបស់លោក ខាងវត្តពោធិពលទៅតែលោកអាចារ្យ ដោក លោកតាំងបង្ហាញព្រះត្រៃបិដកតែសព្វថ្ងៃ មានសិស្សលោកមួយអង្គឈ្មោះកិត្តុ (ឈឺន) ជាអ្នកមានពព្យាយាមច្រើន រៀនព្រះត្រៃបិដកក្នុងសំណាក់លោកអាចារ្យដោក បាន ៤ ឆ្នាំ លាគ្រូទៅរៀនឯស្រុកសៀម ឯក្រោយនោះលោកអាចារ្យដោក សិក្ខទៅបានទទួលទីជាព្រះភក្តីសារពេជ្ញ គឺជាមេខាងក្រុមពួកបណ្ឌិត ទាំងគ្រូសូត្រព្រំក៏សិក្ខទៅផង បានជាក្រុមពួកបណ្ឌិតទទួលទីជាយុះសិទ្ធិវិជ្ជាធម៌ ។

(នៅមានត)